# ទិដ្ឋភាពព្រះរាជពិធីច្រត់ព្រះនង្គ័លក្នុងសង្គមខ្មែរ

គេហទំព័រយើងខ្ញុំបានចុះផ្សាយអំពី ប្រវត្តិ និងអត្ថន័យព្រះរាជពិធីច្រត់ព្រះនង្គ័លក្នុងសង្គមខ្មែរ និងបណ្ដាប្រទេសខ្លះនៅអាស៊ីអាគ្នេយ៍រួចហើយ។[១] ក្នុងឱកាសនេះខ្ញុំសូមបង្ហាញទិដ្ឋភាពពាក់ព័ន្ធខ្លះៗនៃព្រះរាជពិធីច្រត់ព្រះនង្គ័លក្នុងសង្គមខ្មែរ ផ្អែកលើចម្លាក់ គំនូរ និងរូបថតនានា។ បំណងនៃការបង្ហាញនេះ គឺដើម្បីចូលរួមមួយផ្នែកតូច ឱ្យឃើញពីលំអានខ្លះដែលខ្មែរយល់ថាជាឫសគល់នៃទំនៀមព្រះរាជពិធីច្រត់ព្រះនង្គ័ល។ ទន្ទឹមនឹងនោះខ្ញុំសូមសង្ខេបសារបានព្រះរាជពិធីនេះ ដែលតែងប្រារព្ធជាប្រក្រតីចាប់ពីក្រោយរាជ្យ **ព្រះករុណាព្រះបាទ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** រហូតដល់សព្វថ្ងៃ។

បើពោលក្នុងក្របខណ្ឌស្រាវជ្រាវ គេពុំអាចកំណត់ដាច់ណាត់ថា ព្រះរាជពិធីច្រត់ព្រះនង្គ័លក្នុងសង្គមខ្មែរចាប់ប្រារព្ធពីត្រឹមណាឡើយ។ ប៉ុន្តែគេយល់ថា គោលគំនិតធំនៃពិធីនេះប្រហែលចាប់ផ្ដើមតាំងពីខ្មែរជ្រួតជ្រាបអារ្យធម៌ឥណ្ឌា។ ជាក់ស្ដែង យ៉ាងហោចណាស់មានរឿងទេពកថាពីរដែលខ្មែរស្គាល់គឺ រាមកេរ្តិ៍ និងមហាភារត។ បើលើកយករឿងរាមកេរ្តិ៍ជាអំណះអំណាង គេពន្យល់ថានៅត្រង់វគ្គដែលព្រះបាទជនក ព្រះមហាក្សត្រនៃនគរមិថិលាយាងច្រត់ព្រះនង្គ័ល ហើយប្រទះឃើញព្រះនាងសីតានៅនឹងអាចម៍បំណះ គឺជាប្រភពនៃព្រះរាជពិធីច្រត់ព្រះនង្គ័ល។[២]

ក្នុងរឿងមហាភារត គេសំអាងត្រង់ចម្លាក់ព្រះពលទេពកាន់នង្គ័លជាកេតនភ័ណ្ឌដែលឃើញវត្តមានតាំងពីមុនសម័យអង្គរ (រូបលេខ១)។ បដិមាទេពអង្គនេះ ឃើញវត្តមានដល់សម័យអង្គរ (រូបលេខ២) និងបន្តរហូតមកដល់សម័យកណ្ដាលផង។ ក្នុងសម័យកណ្ដាល មន្ត្រីទទួលខុសត្រូវវិស័យកសិកម្មមានងារជា "ឧកញ៉ាពលទេព" ហើយច្បាប់គ្រប់គ្រងវិស័យកសិកម្មឈ្មោះថា "ក្រមពលទេព"។ និមិត្តរូបនេះ គេឃើញជាប់ក្នុងទំនៀមខ្មែរដល់សព្វថ្ងៃ

[១] សូមអាន៖ "ប្រវត្តិ និងអត្ថន័យព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល" ដោយ ឈឿង ប៉ូលីណា https://education.ams.com.kh/history-and-meaning-of-the-royal-ploughing-ceremony/ ផ្សាយថ្ងៃទី២ ខែឧសភា ឆ្នាំ២០២១ និង "ព្រះរាជពិធីច្រត់ព្រះនង្គ័ល" ដោយ មាស សុភាព លើតំណ https://ams.com.kh/khmercivilization/detail/7827 ផ្សាយថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១

[២] *Saveros Pou 1979: 5*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

តាមរយៈទង់ឯកធំក្នុងក្បួនហែព្រះរាជពិធីច្រត់ព្រះនង្គ័ល ដែលមានរូបព្រះពលទេពឈរកាន់នង្គ័ល (រូបលេខ៣)។[៣] រីឯក្នុងព្រះពុទ្ធសាសនា គេយល់ថាព្រះរាជពិធីច្រត់ព្រះនង្គ័ល គឺប្រារព្ធតាមពុទ្ធប្រវត្តិ ត្រង់ពេលព្រះបាទសុទ្ធោទន៍យាងចេញច្រត់ព្រះនង្គ័ល ដោយមានព្រះវត្តមានព្រះសិទ្ធត្ថ។[៤] គ្រានោះ ព្រះសិទ្ធត្ថទ្រង់បានធ្វើសមាធិពិចារណាអំពីសត្វគោដែលប្រឹងប្រែងអូសនង្គ័លយ៉ាងហត់នឿយ (រូបលេខ៤-៦)។[៥]





រូបលេខ១ បដិមាព្រះពលទេព (ស.វ.ទី៦)
រូបលេខ២ ចម្លាក់ក្នុងរឿងមហាភារតនៅប្រាសាទបន្ទាយស្រី

រូបលេខ៣ ទង់ឯកមានរូបព្រះពលទេព នាំក្បួនដង្ហែព្រះរាជពិធីច្រត់ព្រះនង្គ័ល





រូបលេខ៤-៦ ព្រះបាទសុទ្ធោទន៍យាងច្រត់ព្រះនង្គ័ល (គំនូរវត្តកំពង់ត្រឡាចលើ វត្តដំរីស និងវត្តទន្ទាប់រង្សី)

ចាប់ពីសម័យសង្គមរាស្ត្រនិយម ក្នុងរាជ្យ ***ព្រះករុណាព្រះបាទ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ*** ទ្រង់បានចេញច្រត់ព្រះនង្គ័លផ្ទាល់ព្រះហស្តរបស់ព្រះអង្គនៅទីព្រះស្រែស្ថិតនៅក្នុងបរិវេណព្រះលានជល់ដំរីនៃអតីតក្រុងអង្គរធំ ខេត្តសៀមរាប (រូបលេខ៧-៨) និងនៅខេត្តស្វាយរៀង (រូបលេខ៩-១០)។ ក្នុងគ្រានោះ និមិត្តរូបនៃព្រះរាជពិធីច្រត់ព្រះ

[៣] វិទូ ភីរម្យ ២០១២: ៨៨-៩០

[៤] ឈឹម ក្រសេម និង ចាប ពិន ១៩៥១: ១៥២

[៥] Gunapayuta et al 1998: 33-36

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

នង្គ័ល ក៏ឃើញប្រើប្រាស់ផ្សព្វផ្សាយនៅលើតែមប្រៃសណីយ៍ផងដែរ (រូបលេខ១១)។ ប៉ុន្តែក្រោយមក ***ព្រះករុណាព្រះបាទ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ*** ទ្រង់តែងចាត់ព្រះរាជតំណាងច្រត់ព្រះនង្គ័លជំនួសព្រះអង្គ រហូតជាប់ជាទំនៀមដល់សព្វថ្ងៃ។





*រូបលេខ៧-៨ ព្រះរាជពិធីច្រត់ព្រះនង្គ័លនៅអង្គរធំ (ប្រភព៖ FB Royal du Cambodge)*








*រូបលេខ៩-១០ ព្រះរាជពិធីច្រត់ព្រះនង្គ័លនៅខេត្តស្វាយរៀង (ប្រភព៖ FB Royal du Cambodge)*
*រូបលេខ១១ តែមប្រៃសណីយ៍បង្ហាញព្រះរាជពិធីច្រត់ព្រះនង្គ័លទសវត្សទី៦០ (ប្រភព៖ stampboards.com)*

KHMER CIVILIZATION

តាមទំនៀមក្នុងព្រះរាជពិធីទ្វាទសមាស ព្រះរាជពិធីច្រត់ព្រះនង្គ័លក្នុងសង្គមខ្មែរតែងប្រារព្ធជាប្រក្រតី ចាប់ពីថ្ងៃ១រោច ដល់ថ្ងៃ៤រោច ខែពិសាខ។ ពីថ្ងៃ១រោច ដល់ថ្ងៃ៣បរោច ក្រុមបាគូតែងធ្វើកិច្ចជាប្រចាំតាមទំនៀមនៅទីព្រះស្រែ។[៦] លុះដល់ថ្ងៃ៤រោច ព្រះមហាក្សត្រទ្រង់តាំងមន្ត្រីជាន់ខ្ពស់ណាម្នាក់ឱ្យធ្វើជាស្តេចមាឃ ហើយករិយាធ្វើជាមេហួ ដោយយក

[៦] ឈឹម ក្រសេម និង ចាប ពិន ១៩៩១: ៨១-៨៧

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ម្សៅក្រអូបមកចឹមលើថ្ងាសជាកិច្ចសន្មត ចេញច្រត់ព្រះនង្គ័ល (រូបលេខ១២)។[៧] ស្តេចមាយ ស្លៀកសំឡុយចរបាប់ ពាក់អាវផាយ រីឯមេហួក៏ស្លៀកសំឡុយចរបាប់ ពាក់អាវរឹបរាង និង ពាក់ស្បៃឆៀងពីលើ។



រូបលេខ១២ ព្រះមហាក្សត្រទ្រង់ចឹមលើថ្ងាសឯកឧត្តម អ៊ូច ភា និងលោកជំទាវ ជាស្តេចមាយ និងមេហួ ក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័លនៅខេត្តតាកែវ ឆ្នាំ២០១៩ (ប្រភព៖ norodomsihamoni.org)

បន្ទាប់ពីព្រះមហាក្សត្រតែងតាំងតាមទំនៀមរួចស្រេចបាច់ហើយ ស្តេចមេឃត្រូវចូលទៅថ្វាយបង្គំព្រះចន្ទី តាំងនៅពេងមណ្ឌលទិសនិរតី មុននឹងចាប់ដំណើរការច្រត់ព្រះនង្គ័ល។ នង្គ័លច្រត់នាំមុខហៅថា "នង្គ័លយោង" នង្គ័លកណ្តាលកាន់ដោយស្តេចមាយ (រូបលេខ១៣) និងមាននង្គ័លមួយទៀតនៅខាងក្រោយ ឯគោទាំងបីនឹមនោះឈ្មោះថា "គោឧសភរាជ"។ រីឯមេហួ ត្រូវដើរតាមក្រោយនង្គ័លទី៣ ហើយព្រោះគ្រាប់ពូជផ្សេងៗ ដូចជា ល្ង សណ្តែក ពោត និងស្រូវជាដើម (រូបលេខ១៤)។ ដំណើរច្រត់ព្រះនង្គ័លនេះ ចេះតែប្រព្រឹត្តិទៅដោយមានបាគូជាអ្នកដឹកនាំ ដើរតាមទិសទក្ខិណាព័ទ្ធ (ព័ទ្ធស្តាំ)។ លុះគ្រប់បីជុំហើយ គេតែងលែងគោឧសភរាជទាំងនោះឱ្យព្រាហ្មណ៍ព្រោះព្រំ និងផ្សងអំពីផល

[៧] ពេជ្រ សល់ ១៩៦៦: ៣២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដំណាំផ្សេងៗសម្រាប់រដូវកាលធ្វើកសិកម្មថ្មីនេះ (រូបលេខ១៥)។ វត្ថុដែលយកទៅផ្សងនឹងគោឧសភរាជនោះមានប្រាំពីរមុខគឺ ស្រូវ ពោត សណ្តែក ល្ង ស្មៅ ទឹក និងស្រា។ ប្រសិនបើគោឧសភរាជបរិភោគគ្រាប់ពូជណាមួយ ទំនាយថាដំណាំនោះនឹងបានផលល្អ ហើយបើគោឧសភរាជបរិភោគទឹក ទំនាញថានឹងមានភ្លៀងធ្លាក់បរិបូរណ៍។ ប៉ុន្តែផ្ទុយទៅវិញប្រសិនបើគោឧសភរាជបរិភោគស្មៅស្រស់ នោះទំនាយថាស្រុកទេសនឹងកើតមានជំងឺលើសត្វពាហនៈ។ បើគោឧសភរាជបរិភោគស្រា ទំនាយថាស្រុកទេសនឹងកើតមានមនុស្សពាលចោរលួចឆក់ប្លន់ និងអសន្តិសុខក្នុងសង្គម។ ដោយឡែកគេសង្កេតឃើញប្រជាកសិករតែងនាំគ្នាប្រមូលគ្រាប់ស្រូវ ពោត សណ្តែក និងល្ង ដែលបានព្រោះទៅលើដី និងសល់ពីការផ្សងនោះ យកទៅលាយជាមួយគ្រាប់ពូជរបស់ខ្លួន ដោយមានជំនឿថានឹងធ្វើឱ្យដំណាំដាំដុះសម្រាប់ឆ្នាំថ្មីទទួលបានផ្កាផ្លែល្អប្រសើរ (រូបលេខ១៦)។





រូបលេខ១៣-១៤ ព្រះអង្គម្ចាស់ នរោត្តម ចក្រាវុធ្ឍ និងព្រះមហាក្សត្រីយ៍ ស៊ីសុវត្ថិ ចាន់ស៊ីដា យាងជាស្តេចមាឃ និងមេហ្គ ក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល ប្រារព្ធនៅទីព្រះស្រែវាលព្រះមេរុ



រូបលេខ១៥ កិច្ចផ្សងគោឧសភរាជ



រូបលេខ១៦ ប្រជាពលរដ្ឋរើសគ្រាប់ពូជ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ក្រោយបានសន្តិភាព ព្រះរាជពិធីច្រត់ព្រះនង្គ័លក៏ចាប់ផ្ដើមប្រារព្ធតាមប្រពៃណីឡើងវិញ។ ក្នុងឆ្នាំ១៩៩៣ បានរៀបចំឡើងនៅក្នុងបរិវេណពហុកីឡដ្ឋានជាតិអូឡាំពិក ហើយចាប់ពីឆ្នាំ១៩៩៤ រហូតមក ព្រះរាជពិធីនេះតែងរៀបចំប្រារព្ធនៅវាលព្រះមេរុ ក្បែរព្រះបរមរាជវាំង (ឆ្នាំ២០១០ ប្រារព្ធនៅសៀមរាប)។ ប៉ុន្តែចាប់ពីក្រោយ ***ព្រះករុណា ព្រះបាទ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ*** សោយព្រះទិវង្គត គេសង្កេតឃើញព្រះរាជពិធីច្រត់ព្រះនង្គ័ល តែងរៀបចំប្រារព្ធតាមបណ្ដាខេត្តដូចជា ឆ្នាំ២០១៣ នៅខេត្តកំពង់ចាម ឆ្នាំ២០១៤ នៅខេត្តកណ្ដាល ឆ្នាំ២០១៥ នៅខេត្តបាត់ដំបង ឆ្នាំ២០១៦ នៅខេត្តសៀមរាប ឆ្នាំ២០១៧ នៅខេត្តព្រៃវែង ឆ្នាំ២០១៨ នៅខេត្តស្វាយរៀង ឆ្នាំ២០១៩ នៅខេត្តតាកែវ និងចាប់ពីឆ្នាំ២០២០ មកព្រះរាជពិធីនេះត្រូវបានផ្អាកដោយសារវិបត្តិកូវីដ-១៩៕

## ឯកសារយោង

ចាប ពិន

១៩៦០, *ព្រះរាជពិធីទ្វាទសមាស*, ភាគ៣, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ឈឹម ក្រសេម និង ចាប ពិន

១៩៥១, *ព្រះរាជពិធីទ្វាទសមាស*, ភាគ២, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ពេជ្រ សល់

១៩៦៦, *ពិធីប្រចាំដប់ពីរខែ,* ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

វិទូ ភីរម្យ,

២០១២, "ពលរាម ឬពលទេព", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ៧, ទំ. ៨៨-៩០, យសោធរ, ភ្នំពេញ

Gunapayuta et al,

1998, *Biography of Sakyamuni Buddha,* Sydney

Saveros Pou

1979, *Rāmaketi (XVI-XVIIè siècle),* EFEO, Paris

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត